# អនុក្រឹត្យលេខ ០៥ អនក្រ.បក
# ស្តីពីវិសោធនកម្មលើមាត្រា ៣ ជំពូកទី២ អំពីលិខិតឆ្លងដែនការទូត នៃអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០០០ ស្តីពីការផ្តល់ និងការប្រើប្រាស់លិខិតឆ្លងដែនការទូត ផ្លូវការ

===

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ ០៥ នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីអន្តោប្រវេសន៍
- បានឃើញអនុក្រឹត្យលេខ ៦៨.អនក្រ. ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់ដើម្បីរៀបចំធ្វើបដិការទិដ្ឋាការ ដល់លិខិតឆ្លងដែនការទូត និងលិខិតឆ្លងដែនផ្លូវការជាមួយបណ្តារដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០០
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០០

## សំរេច

**មាត្រាតែមួយ.-**

មាត្រា៣ ជំពូកទី២ អំពីលិខិតឆ្លងដែនការទូត នៃអនុក្រឹត្យលេខ ៥១ អនក្រ.បក ស្តីពីការផ្តល់ និងការប្រើប្រាស់លិខិតឆ្លងដែនការទូត -ផ្លូវការ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០០ ត្រូវបានកែប្រែឱ្យទៅជាមាត្រា ៣ ថ្មី ដែលមានខ្លឹមសារដូចតទៅ :

**មាត្រា ៣ ថ្មីជំនួសមាត្រា ៣ ចាស់ :**

ក- លិខិតឆ្លងដែនការទូត ចេញថ្វាយ និងជូនដល់សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា ព្រមទាំងស្វាមី ឬភរិយា (សហព័ទ្ធ) ផងដែរ តែពុំអាចផ្តល់ជូនដល់កូននៅក្នុងបន្ទុក ទោះបីជាកូននោះនៅលីវ ឬមានអាយុក្រោម ១៨ឆ្នាំ (ក៏ដោយ) ។

ខ- លិខិតឆ្លងដែនការទូត ចេញថ្វាយ និងជូនដល់មន្ត្រីរាជការ និងឥស្សរជនជាន់ខ្ពស់ខ្មែរទៅតាមលំដាប់នៃឋានន្តរសក្តិ និងមុខតំណែងដូចខាងក្រោម ។ ភរិយា ឬស្វាមី (សហព័ទ្ធ) ព្រមទាំងកូននៅក្នុងបន្ទុករបស់មន្ត្រីរាជការ និងឥស្សរជនទាំងនោះ ពុំអាចផ្តល់ជូនលិខិតឆ្លងដែនការទូតកាន់ជាមួយទេ ។

១- ប្រធាន និងអនុប្រធាន គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត និងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

២- រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ នៃក្រសួងស្ថាប័ននានា ។

៣- អគ្គលេខាធិការរងរាជរដ្ឋាភិបាល អគ្គទេសាភិបាលរងធនាគារជាតិ ។

៤- អនុប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

៥- មន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ ចាប់ពីថ្នាក់អគ្គនាយក អគ្គាធិការឡើងទៅដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័ន ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ។

៦- មន្ត្រីផ្នែកយោធា ដែលមានឋានៈចាប់ពីប្រធានអគ្គនាយកដ្ឋានចំណុះក្រសួងការពារជាតិឡើងទៅអគ្គមេបញ្ជាការរង នាយសេនាធិការចំរុះ នាយរងសេនាធិការចំរុះ មេបញ្ជាការកងទ័ពជើងគោក មេបញ្ជាការកងទ័ពជើងអាកាស មេបញ្ជាការកងទ័ពជើងទឹក នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងមន្ត្រីផ្នែកនគរបាលដែលមានឋានៈជាអគ្គនាយករងនគរបាលជាតិ ។

៧- ទីប្រឹក្សាដែលមានឋានៈស្មើអនុរដ្ឋលេខាធិការឡើងទៅ ។

៨- អតីតឧបនាយករដ្ឋមន្ត្រី ។

៩- ប្រតិភូរាជរដ្ឋាភិបាលដែលទទួលបន្ទុកជាអភិបាល អភិបាលរងរាជធានីភ្នំពេញ អភិបាលខេត្ត-ក្រុង ។

១០- ប្រធានពិធីការរបស់ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ព្រឹទ្ធសភា រដ្ឋសភា ក្រសួងការបរទេស ។

**អវសានប្បញ្ញត្តិ**

មាត្រា ៣ ជំពូកទី២ អំពីលិខិតឆ្លងដែនការទូត នៃអនុក្រឹត្យលេខ ៥១-អនក្រ.បក ស្តីពីការផ្តល់ និងប្រើប្រាស់លិខិតឆ្លងដែនការទូត ផ្លូវការ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០០ ត្រូវទុកជានិរាករណ៍ ។

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសូមចុះហត្ថលេខា

ហត្ថលេខា

**ហោ ណាំហុង**

រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

***

## អនុក្រឹត្យ

## អនុក្រឹត្យលេខ ០៨ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

===

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា